**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៥

នៅក្នុងខែមករា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បីពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង
- បានរៀបចំបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បីពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

### ២-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖
  - ❖ គណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ និងយាងចុះជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួង ដឹកនាំដោយ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីស្វែងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម ឆ្នាំ២០២៤ និងចក្ខុវិស័យរបស់ក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ២០២៥ នៅក្រសួងធនធានទឹក និងឧតុនិយម។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

❖ គណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងចុះតាមដានការអនុវត្តច្បាប់ និងតុលាការ នៅខេត្តស្វាយរៀង និង

❖ គណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលខេត្តកំពត ដើម្បីសិក្សាស្វែងយល់អំពីៈ

១/ ការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការគ្រប់គ្រងជនបរទេស

២/ ការអនុវត្តច្បាប់ស្តីពី របបសារព័ត៌មាន និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ខេត្ត ដូចជា វិទ្យុ ទូរទស្សន៍ និងព័ត៌មានតាមបណ្តាញសង្គម

៣/ ការផ្តល់ប័ណ្ណការងារជូនជនបរទេស និងការត្រួតពិនិត្យប័ណ្ណការងាររបស់ជនបរទេស ដែលកំពុងធ្វើការនៅតាមរោងចក្រ សហគ្រាស និងក្រុមហ៊ុននានា

៤/ កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិ ជាមួយអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិនៃប្រទេសជិតខាង

៥/ ការអភិវឌ្ឍលើវិស័យនានារបស់ខេត្តទាំងពីរ និង

៦/ ការពង្រឹងពង្រីកទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងព្រឹទ្ធសភា ជាមួយអាជ្ញាធរខេត្តទាំងពីរគ្រប់លំដាប់ថ្នាក់។

## ៣-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាៈ

**❖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាបានៈ**

- អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំ ចំនួន២លើក រួមមានៈ
  - បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក។
- សកម្មភាពចូលរួមពិធីផ្សេងៗ ចំនួន១លើកៈ
  - បានអញ្ជើញជាអធិបតីក្នុងពិធីមិទ្ទីញអបអរសាទរខួបលើកទី៤៦ នៃទិវាជ័យជម្នះ៧ មករា ១៩៧៩ - ៧ មករា ២០២៥ នៅខាងមុខសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។

**❖ ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភាបានៈ**

- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំនានា ចំនួន៤លើក រួមមានៈ
  - បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំរួមរវាងតំណាងព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញស្តីពីសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅសាលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីពិនិត្យ

ពិភាក្សាលើការអនុវត្តសកម្មភាពនៃក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ក្នុងឆ្នាំ ២០២៤។

- បដិសណ្ឋារកិច្ចភ្ញៀវជាតិ ចំនួន១លើក៖
  - បានអនុញ្ញាតឱ្យក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ចូលជួបសម្តែងការគួរសម និងជូនពរក្នុងឱកាសដែល **ឯកឧត្តម** ត្រូវបានព្រឹទ្ធសភាបោះឆ្នោតជ្រើសរើសជាអនុប្រធានទី១ព្រឹទ្ធសភា។
- សកម្មភាពចុះមូលដ្ឋាន ចំនួន១លើក៖
  - បានចាត់ **ឯកឧត្តម ឡាន់ ឆន** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ជាតំណាង អញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំទូទាំងស្រុកមេមត់ និងស្រុកពញាក្រែក ក្នុងខេត្តត្បូងឃ្មុំ ដោយមានអ្នកចូលរួម ចំនួន២៦៩នាក់។
- សកម្មភាពចូលរួមពិធីផ្សេងៗ ចំនួន២លើក៖
  - បានអញ្ជើញចូលរួមក្នុងពិធីបើកការប្រកួតកីឡាវាយកូនគោលពានរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** លើកទី៨ ឆ្នាំ២០២៤ នៅទីលានកីឡាវាយកូនហ្គោល ឈុន អូន ហ្គហ្វ រីស៊ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល និង
  - បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកជំទាវធម្មសទ្ធាភិរក្ខ័សិរីវិសុទ្ធិរតន៍ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **យស់ ស៊ីមន** ភរិយារបស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉ឹង សំផន** រដ្ឋលេខាធិការក្រសួងការពារជាតិ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទង្សោ អនុប្រធានទី២ព្រឹទ្ធសភាបាន៖**

- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំនានា ចំនួន៤លើក រួមមាន៖
  - បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក។
  - បានអញ្ជើញជួបប្រជុំជាមួយថ្នាក់ដឹកនាំនៃវិទ្យាស្ថានស្ថិតិ នៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា និង
  - បានអញ្ជើញជួបប្រជុំជាមួយថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅវិមានព្រឹទ្ធសភា។
- បដិសណ្ឋារកិច្ចភ្ញៀវជាតិ ចំនួន១លើក៖
  - បានជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្តារកសិកម្ម នៅកម្ពុជា នៅវិមានព្រឹទ្ធសភា។
- សកម្មភាពចុះមូលដ្ឋាន ចំនួន១លើក៖
  - បានអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌចំការមន និងខណ្ឌបឹងកេងកង សរុបចំនួន២៦៥នាក់ នៅសាលប្រជុំសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ។

- សកម្មភាពចូលរួមពិធីផ្សេងៗ ចំនួន៤លើក រួមមាន៖
  - បានអញ្ជើញជាកិត្តិយសក្នុងពិធីមីទិញអបអរសាទរខួបលើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩ - ៧ មករា ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅខាងមុខសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រឹត្តិការណ៍បាល់ទាត់មិត្តភាពដើម្បីអបអរសាទរ " ទិវាសន្តិភាពនៅកម្ពុជា " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត** នៅពហុកីឡដ្ឋានមរតកតេជោ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
  - បានអញ្ជើញចូលរួមជាអធិបតីក្នុងវេទិកាផ្សព្វផ្សាយ " វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លី-បរិយាកាសគ្មានវិវាទ " នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា និង
  - បានអញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកាស្តីពី " ពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងជាសហគ្រិនស្ត្រី រួមទាំងវិស័យឌីជីថល " នៅខេត្តកំពត។

❖ **សមាជិក សមាជិកាព្រឹទ្ធសភាបាន៖**

- បានអញ្ជើញជាកិត្តិយសក្នុងពិធីមីទិញអបអរសាទរខួបលើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩ - ៧ មករា ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅខាងមុខសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។
- បានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ចំនួន ១ខ្នង នៃវិទ្យាល័យ ហេង សំរិន ចក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហា-ពញាចក្រី ហេង សំរិន ប្រធានកិត្តិយស**នៃក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅខេត្តត្បូងឃ្មុំ។
- បានអញ្ជើញចូលរួមជាគណៈអធិបតី និងជាភ្ញៀវកិត្តិយសក្នុងវេទិកាផ្សព្វផ្សាយស្តីពី " វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លី-បរិយាកាសគ្មានវិវាទ " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា** និង**ឯកឧត្តម វង សូត អនុប្រធានទី២រដ្ឋសភា** នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។
- បានអញ្ជើញ និងយាងជាកិត្តិយសក្នុងវេទិកាស្តីពី " ពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងជាសហគ្រិនស្ត្រី រួមទាំងវិស័យឌីជីថល " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា** នៅខេត្តកំពត។
- បានអញ្ជើញចូលរួមវេទិកាសាធារណៈជាមួយក្រុមប្រឹក្សាសង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាល មេភូមិទាំង១៣ និងប្រជាពលរដ្ឋ សរុបចំនួន៦២នាក់ ដើម្បីស្តាប់សំណូមពរ និងកង្វល់នានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធការអនុវត្តគោលនយោបាយភូមិ សង្កាត់ មានសុវត្ថិភាព ស្ថិតនៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន នៅខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌចំការមន និងខណ្ឌបឹងកេងកង សរុបចំនួន២៦៥នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅសាលប្រជុំសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដឹកនាំដោយ **ឯកឧត្តម ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នៅខេត្តឧត្តរមានជ័យ។
- បានអញ្ជើញប្រជុំពិភាក្សាការងារជាមួយនាយកប្រតិបត្តិមជ្ឈមណ្ឌលសភាអាស៊ី PCAsia និងសហការី នៅសាលប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា លើរបៀបវារៈ៖

  ១/ បង្ហាញសមាសភាពសមាជិកគណៈកម្មការទី១ និងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការ

  ២/ ស្តាប់បទបង្ហាញអំពីបេសកកម្មការងាររបស់ PCAsia នៅក្នុងប្រទេសកម្ពុជា និង

  ៣/ កិច្ចសហប្រតិបត្តិការការងារ។
- បានអញ្ជើញទទួលជួបប្រជាពលរដ្ឋមកពីឃុំស្បា ឃុំរាំងទិល និងឃុំកំពង់លួង ខេត្តពោធិ៍សាត់ ចំនួន១០០នាក់ និងប្រជាពលរដ្ឋអញ្ជើញមកពីខេត្តសៀមរាប ចំនួន៥០នាក់ អញ្ជើញមកសិក្សាស្វែងយល់វិស័យកសិកម្ម និងកសិ-ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវស្ពាន ទំនប់ទឹក និងចំការដំណាំហូបផ្លែច្រើនប្រភេទ នៅខេត្តកំពង់ស្ពឺ។
- បានអញ្ជើញទទួលជួបលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មកពីសាលា Milky Way ចំនួន ១៥២នាក់ អញ្ជើញមកសិក្សាស្វែងយល់វិស័យកសិកម្ម និងកសិ-ទេសចរណ៍ នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ។
- បានអញ្ជើញ និងយាងជាកិត្តិយសក្នុងព្រឹត្តការណ៍សាទរកម្ពុជា ដែលរៀបចំឡើងដោយសហភាពសហព័ន្ធយុវជនកម្ពុជា( ស.ស.យ.ក ) នៅខាងមុខព្រះបរមរាជវាំង រាជធានីភ្នំពេញ។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា (AMH) របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅមណ្ឌលសុខភាពបឹងព្រះ ខេត្តព្រៃវែង។
- បានសហការជាមួយអង្គការសង្គ្រោះវេជ្ជសាស្ត្រអន្តរជាតិប្រចាំកម្ពុជា អញ្ជើញចុះពិនិត្យ និងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ សរុបចំនួន៥៦០នាក់ នៅខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌកំបូល និងខណ្ឌដង្កោ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន២លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

  ១/ ព្រឹត្តិការណ៍បាល់ទាត់មិត្តភាព ដើម្បីអបអរសាទរ " ទិវាសន្តិភាពនៅកម្ពុជា " និង

  ២/ ពិធីប្រកាសខេត្តកំពង់ចាម បញ្ចប់ការវាស់វែងដីធ្លីជាលក្ខណៈប្រព័ន្ធ និងពិធីចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម។

- ❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ស្វែងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្តនានា **ចំនួន១០៤លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន៩៣លើក**។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - ▪ អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក។
  - ▪ អញ្ជើញអម **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា** និង**លោកជំទាវ ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមការងារនៃក្រុមប្រឹក្សាធម្មនុញ្ញស្តីពី វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា និង
  - ▪ អញ្ជើញប្រជុំជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះពិនិត្យ និងពិភាក្សាការងារ ដើម្បីត្រៀមលក្ខណៈរៀបចំពិធីកាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា និងសមិទ្ធផលនានា ជាអំណោយដ៏ថ្លៃថ្លាបំផុតរបស់ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ស្ថិតនៅក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
- ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - ▪ អញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារដំណើរការសាងសង់អគារថ្មីព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានក្រុមការងារសាងសង់អគារថ្មីព្រឹទ្ធសភា នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង
  - ▪ អញ្ជើញចូលរួមពិធីមីទ្ទិញអបអរសាទរខួបលើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩ - ៧ មករា ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ។
- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញអម **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ចុះពិនិត្យ និងពិភាក្សាការងារ ដើម្បីត្រៀម

លក្ខណៈរៀបចំពិធីកាត់ខ្សែបូសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា និងសមិទ្ធផលនានា ស្ថិតនៅក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ខេត្តកណ្ដាល។

- **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូវ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរង ព្រឹទ្ធសភា បានអញ្ជើញជូន និងទទួលដំណើររបស់ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា** ដឹកនាំគណៈប្រតិភូកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅរដ្ឋធានីហាណូយ និងចូលរួមកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) នៅខេត្តកាន់ថឺ សាធារណរដ្ឋ សង្គមនិយមវៀតណាម នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូវ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញ ចូលរួមពិធីសំណេះសំណាលរវាងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជាមួយអាជ្ញាធរ មូលដ្ឋាន នៅខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌចំការមន និងខណ្ឌបឹងកេងកង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី១ នៅសាលប្រជុំសាលាខណ្ឌដូនពេញ រាជធានីភ្នំពេញ។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញ ចូលរួមវេទិកាផ្សព្វផ្សាយស្ដីពី " វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លី-បរិយាកាសគ្មានវិវាទ " ក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា** និង **ឯកឧត្តម វង សូត អនុប្រធានទី២រដ្ឋសភា** នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងសម័យប្រជុំ ព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក និង
  - អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកម្មវិធី ផ្សេងៗ ចំនួន៦លើក។
- **ឯកឧត្តម អោក ប៉ូវ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធនិម្មិតស្ដីពី " ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ " ជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
  - អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកម្មវិធី ផ្សេងៗ ចំនួន៣លើក។
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌កម្ពុជា (AMH) របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
  - អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកម្មវិធី ផ្សេងៗ ចំនួន២លើក។

- បានរៀបចំចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ក្នុងឱកាសនៃខួបចំណងអាពាហ៍ពិពាហ៍៤៩ឆ្នាំ របស់សម្ដេចទាំងទ្វេ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
  - **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អគ្គស្នងការនៃសមាគមកាយឫទ្ធិនារីកម្ពុជា និង
  - **សម្ដេចក្រឡាហោម ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គោរពជូន៖
  - **ឯកឧត្ដមនាយឧត្ដមសេនីយ៍ ម៉ឹង សំផន** រដ្ឋលេខាធិការក្រសួងការពារជាតិ ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់លោកជំទាវធម្មសទ្ធាកិត្តិសិរីវិសុទ្ធិរតន៍ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **យស់ ស៊ីមន**។
  - **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ហាក់ ស៊ីផេន**។
  - **ឯកឧត្តម មាស សុភា** ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាតំណាងរាស្ត្រមណ្ឌលខេត្តព្រះវិហារ ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់មហាឧបាសិកា **គង់ លាន់**។
  - **ឯកឧត្ដម ឈួន ឡេង** អនុប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់មហាឧបាសិកា **ឈួន នាង** និង
  - **ក្រុមគ្រួសារសព លោក អឿន ចាន់ដារ៉ា** និង**លោក ពៅ នេពីន** អ្នកឯកទេសបោសសំអាតមីនរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ក្នុងឧបទ្ទវហេតុផ្ទុះមីនតោន នៅក្នុងភូមិត្រពាំងប្រិយ៍ ឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
- បានទទួលពាក្យបណ្ដឹង ចំនួន៥បណ្ដឹង ធ្វើកំណត់បង្ហាញពាក្យបណ្ដឹង ចំនួន៧បណ្ដឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ចំនួន៣បណ្ដឹង កំពុងពិនិត្យសិក្សា ចំនួន៥បណ្ដឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន ៤បណ្ដឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា ចំនួន៣លើក រួមមាន៖

- **ឯកឧត្តមបណ្ឌិត តាន់ស្រ៊ី ដាតូ ចូហារិ ប៊ិន អាប់ឌុល** (Tan Sri Dato′ Dr. Johari bin Abdul) ប្រធានរដ្ឋសភានៃប្រទេសម៉ាឡេស៊ី។
- **ឯកឧត្តម ជែម កាម៉ាល់ ខាន់** (Jam Kamal Khan) រដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន និង
- បានអនុញ្ញាតឱ្យ **ឯកឧត្តម អាលី អាកបារ ណាហ្សារី** (Ali Akbar Nazari ) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភាបាន៖**

- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅរដ្ឋធានីហាណូយ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) នៅខេត្តកាន់ថឺ សាធារណរដ្ឋសង្គមនិយមវៀតណាម។
- អញ្ជើញពិសាអាហារថ្ងៃត្រង់ការងារជាមួយ **ឯកឧត្តម ដាមីយ៉ែន សេសសឺឡាំង** (Damien Cesselin) អគ្គលេខាធិការនៃសភាប្រើភាសាបារាំង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នសភាកម្ពុជា និងសភាប្រើភាសាបារាំង នៅភោជនីយដ្ឋានក្រវាញ រាជធានីភ្នំពេញ និង
- អញ្ជើញពិសាអាហារពេលព្រឹកការងារជាមួយភារធារីស្តីទីនៃស្ថានទូតអាម៉េរិកប្រចាំកម្ពុជា នៅសាលពិសេសខាងជើង វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធុរ៉ានា អនុប្រធានទី២ព្រឹទ្ធសភា** បានអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគជប៉ុន ចូលជួបពិភាក្សាការងារ នៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា ចំនួន២លើក ដើម្បីពិភាក្សាអំពី៖

១/ ការកសាងមជ្ឈមណ្ឌលអាហារូបត្ថម្ភ និងទារកដ្ឋាន និង

២/ ការកសាងមជ្ឈមណ្ឌលស្រាវជ្រាវចំណីអាហារ និងការបណ្តុះបណ្តាល។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា និង**ឯកឧត្តម ង៉ាន់ ចំរើន** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ីស្តីពី កិច្ចការនយោបាយ នៅទីក្រុងបាកដាដ ប្រទេសអ៊ីរ៉ាក់។

❖ **ឯកឧត្តម ជឹម លាវ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង(APF) នៅខេត្តកាន់ថឺ សាធារណរដ្ឋសង្គមនិយមវៀតណាម។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា **ឯកឧត្តម ឈួន ឆាម** អនុប្រធាន **ឯកឧត្តម លេង វី** លេខាធិការ និង**ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិក បានអញ្ជើញជួបប្រជុំជាមួយគណៈប្រតិភូក្រុមហ៊ុន Cropmate Fertilizer Sdn.Bhd ដែលជាក្រុមហ៊ុនផលិតជីពាក់កណ្តាលសរីរាង្គ និងជីគីមី ដឹកនាំដោយ **លោក Lee Chin Yok** អគ្គនាយកក្រុមហ៊ុន ដើម្បីស្វែងយល់ពីវិស័យកសិកម្ម កសិ-ឧស្សាហកម្ម នៅតំបន់កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

ខេត្តកំពង់ស្ពឺ និងតំបន់កសិកម្ម កសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ម៉ុង ឬទ្ធី គ្រុប ខេត្តព្រះសីហនុ ព្រមទាំងពិនិត្យមើលទីតាំងសាងសង់រោងចក្រផលិតដី នៅសាលប្រជុំពិសេស៣ព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀង ក្នុងឱកាសបញ្ចប់បេសកកម្មការទូតរបស់ **លោកវេជ្ជបណ្ឌិត Devyani Khobragade** ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជា នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតឥណ្ឌា រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូមូលនិធិសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីសហការរៀបចំកម្មវិធីប្រគំតន្ត្រីសប្បុរសធម៌កម្ពុជា-កូរ៉េ នៅទីស្តីការក្រសួងទេសចរណ៍ រាជធានីភ្នំពេញ និង

❖ **សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជាគណៈអធិបតីក្នុងពិធីសម្ពោធស្ពានបេតុងមិត្តភាពកម្ពុជា-ចិន នៅខេត្តបន្ទាយមានជ័យ។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

  - អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងជំនួបសម្តែងការគួរសមជាមួយភ្ញៀវអន្តរជាតិ នៅវិមានព្រឹទ្ធសភា ចំនួន៣លើក។
  - អញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់ការងារ រៀបចំដោយ **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា** ជូន **ឯកឧត្តម ដាមីយ៉ែន សេសសឺឡាំង** (Damien Cesselin) អគ្គលេខាធិការនៃសភាប្រើភាសាបារាំង(APF) នៅភោជនីយដ្ឋានក្រវាញ។
  - អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា** ពិសាអាហារពេលព្រឹកការងារជាមួយលោកជំទាវ Bridgette L. Walker ភារធារីស្តីទីនៃស្ថានទូតអាម៉េរិកប្រចាំកម្ពុជា នៅសាលពិសេសខាងជើង វិមានព្រឹទ្ធសភា។
  - អញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់ការងារ រៀបចំដោយ **លោក Nagase Kensuke** អនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា និងមន្ត្រីស្ថានទូត និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងស្តីពី ការរៀបចំដំណើរទស្សនកិច្ចរបស់ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** នាពេលខាងមុខ នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតចូលរួមសោកស្តាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** គោរពជូន **ឯកឧត្តម ស៊ី ជីនពីង** (Xi Jinping) ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ចំពោះគ្រោះធម្មជាតិរញ្ជួយដី នៅតំបន់ស្វយ័តស៊ីនជាំង ភាគនិរតីនៃសាធារណរដ្ឋប្រជាមានិតចិន។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** គោរពជូន **លោកជំទាវ ស៊ូ ឡាញ** (Sue Lines) ប្រធានព្រឹទ្ធសភាប្រទេសអូស្ត្រាលី ក្នុងឱកាសទិវាបុណ្យជាតិអូស្ត្រាលី។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីចិន និងវៀតណាម គោរពជូន៖
  ១/ **ឯកឧត្តម ស៊ី ជីនពីង** ( Xi Jinping ) ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន
  ២/ **ឯកឧត្តម វ៉ាង ហ៊ូនីង** ( Wang Huning ) ប្រធានគណៈកម្មាធិការជាតិ សភាប្រឹក្សានយោបាយប្រជាជនចិន
  ៣/ **ឯកឧត្តម ចាវ ឡឺជី** ( Zhao Leji ) ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ សភាតំណាងប្រជាជនចិន ( NPC )
  ៤/ **ឯកឧត្តម លី ឈាង** ( Li Qiang ) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន
  ៥/ **ឯកឧត្តម តូ ឡឹម** ( To Lam ) អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម
  ៦/ **ឯកឧត្តម លឿង គឿង** ( Luong Cuong ) ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
  ៧/ **ឯកឧត្តម ជិន ថាញ់មិន** ( Tranh Tanh Man ) ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង
  ៨/ **ឯកឧត្តម ផាម មិនជីញ** ( Pham Minh Chinh ) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- ចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **លោកជំទាវ ហ្សាស៊ី ហ្គាហ្វារ៉ូវ៉ា** ( Sahiba Gafarova ) ប្រធានរដ្ឋសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតទំនាក់ទំនងការទូតរវាងសាធារណរដ្ឋអាស៊ែបៃហ្សង់ និងព្រះរាជាណាចក្រកម្ពុជា។
- បានចាត់ចែងបញ្ជូនសារលិខិតរបស់ **ឯកឧត្តម ស៊ី ជីនពីង** ( Xi Jinping ) ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដែល **សម្តេចតេជោ** បានផ្ញើសារលិខិតចូលរួមរំលែកទុក្ខជូន **ឯកឧត្តម** ចំពោះគ្រោះធម្មជាតិរញ្ជួយដី នៅតំបន់ស្វយ័តស៊ីជាំង ភាគនិរតីនៃសាធារណរដ្ឋប្រជាមានិតចិន និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន មជ្ឈមណ្ឌលសភាអាស៊ី ( PCAsia ) មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន( CALRC ) បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា( CADT ) ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេស និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញដឹកនាំក្រុមការងារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីពិភាក្សាត្រៀមរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានរដ្ឋសភា និង

- អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ ឆ្នាំ២០២៤ និងទិសដៅការងារខែមករា ឆ្នាំ២០២៥ នៅសាលខាងជើង វិមានព្រឹទ្ធសភា។

### ៥.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានរៀបចំរបាយការណ៍ឧបសម្ព័ន្ធនៃរបាយការណ៍អនុវត្តចំណូល-ចំណាយថវិកាជាតិរបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២៤។
- បានស្នើសុំបុរេប្រទាន សម្រាប់៖
  - ដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅរដ្ឋធានីហាណូយ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) នៅខេត្តកាន់ថឺ សាធារណរដ្ឋសង្គមនិយមវៀតណាម និង
  - ដឹកនាំគណៈប្រតិភូកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី កិច្ចការនយោបាយនៃសភាតំបន់អាស៊ី(APA) នៅទីក្រុងបាកដាដ ប្រទេសអ៊ីរ៉ាក់។
- បានទូទាត់ថវិកាបុរេប្រទាន ចំណាយលើ៖
  - បេសកកម្មក្រៅប្រទេសរបស់គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា ដឹកនាំដោយ **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត រដ្ឋកាតា សាធារណរដ្ឋតួកគីយ៉េ ប្រទេសអេមីរ៉ាតអារ៉ាប់រួម និងចូលរួមវេទិកាចំណេះដឹងពិភពលោកលើកទី២៥ ក្រោមប្រធានបទ " ដំណើរឆ្ពោះទៅរក សហត្ថិភាព " និងកម្មវិធីពាក់ព័ន្ធ នៅទីក្រុងអ៊ីនធន់ សាធារណរដ្ឋកូរ៉េ។
  - បេសកកម្មក្រៅប្រទេសរបស់គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៤៩ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស និង
  - បេសកកម្មក្រៅប្រទេសរបស់គណៈប្រតិភូកម្ពុជា ចំនួន៥រូប អញ្ជើញចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង(APF)។
- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែមករា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈប្រព័ន្ធធនាគារ។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៥សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន២៤សំណើ។
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារ

អនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មវិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២៩សំណើ។

- បានថតចម្លងឯកសារ ចំនួន១០,៣២៩ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន២១,៣១២សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តទាំង៨ ភូមិភាគ ចំនួន៦០លើក ស្មើនឹង២០២នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៣១លើក ស្មើនឹង៨០៨នាក់។
- បានទទួលលិខិតចូល ចំនួន១,៣១៥ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន១,១៣៤ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤៣ច្បាប់ ស្មើនឹង២១៣នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៧ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាពនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១នាក់។
- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៦លើក និងបានសម្អាតបរិស្ថានអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥ រួមមាន៖
  - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧១៧នាក់ (ប្រុស៤២៥នាក់ ស្រី២៩២នាក់)។
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៤នាក់ (ប្រុស៤៩នាក់ ស្រី៣៥នាក់)។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៤នាក់ (ប្រុស៣០៧នាក់ ស្រី១៨៧នាក់)។
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១០នាក់ និង
  - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន៣នាក់។
- បានធ្វើសេចក្តីសម្រេច ចំនួន៣ច្បាប់ និងលិខិតបង្គាប់ការ ចំនួន២ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្តង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន២ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមករា ឆ្នាំ២០២៥ (មន្ត្រីរាជការស្នើសុំបញ្ចូលប្រាក់ឧបត្ថម្ភសម្រាប់កូន ចំនួន៤នាក់)។
- បានរៀបចំបែបបទ និងសំណើសុំប័ណ្ណសមាជិក(ប.ស.ស) ជូនមន្ត្រីរាជការជ្រើសរើសថ្មី និងផ្លាស់ប្តូរប័ណ្ណសមាជិក(ប.ស.ស) ដែលផុតកំណត់ប្រើប្រាស់ ជូនជំនួយការថ្នាក់ដឹកនាំ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១១នាក់។
- បន្តយកចិត្តទុកដាក់ចូលរួមក្នុងដំណើរការកសាងអគារថ្មីព្រឹទ្ធសភា។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមាន៖
  - បានប្តូរអ្វូតូទ្វារអាលុយមីញ៉ូម នៅសាលខាងជើង វិមានព្រឹទ្ធសភា។

- បានបាំងបន្ទប់កញ្ចក់ និងជួសជុលទ្វារឈើក្បាច់ នៅខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា។
- បានគាស់ការ៉ូបាត និងជួសជុលទុយោទឹកបែកនៅខាងក្រោយប៉ុស្តិ៍យាម P1។
- បានជួសជុលម៉ូទ័រទ្វារ នៅច្រកចេញ-ចូល P1។
- បានធ្វើស្លាកឈ្មោះបន្ទប់ថ្មី ជូននាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា ចំនួន ១ស្លាក និង
- បានសហការជាមួយអគ្គិសនីកម្ពុជា(EDC) លើកត្រង់ស្វូទូសុវត្ថិភាព និងចាក់សាបឱ្យបានខ្ពស់។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន១២៨គ្រឿង/លើក។
- បានបំពាក់ស្លាកលេខរថយន្តខ្នាតវែងព្រឹទ្ធសភា ជូនសមាជិកព្រឹទ្ធសភា ចំនួន៤គ្រឿង។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥ និង
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។

## ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច និងសារាចរ ចំនួន១៥ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានធ្វើជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ជូន **សម្តេចតេជោ ប្រធានព្រឹទ្ធសភា** ចំនួន២លើក ។
- បានធ្វើជំនួយស្មារតីជូនលេខាធិការសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- បានរៀបចំបែបបទ នីតិវិធី ឯកសារពាក់ព័ន្ធនឹងកិច្ចប្រជុំជូនគណៈកម្មការទី៦ព្រឹទ្ធសភា ដើម្បីពិនិត្យស្នើសុំធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន២លើក។
- បានសម្រួលដំណើរការបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំ ចប់អាណត្តិ ឬលាលែងពីមុខតំណែង និងទទួលការតែងតាំងថ្មី សម្រាប់នីតិកាលទី៥ ចាប់ពីថ្ងៃទី១-១៦ ខែមករា ឆ្នាំ២០២៥ ចំនួន១២៥នាក់។

- បានផ្ទៀងផ្ទាត់បុគ្គលចប់អាណត្តិ ឬលាលែងពីមុខតំណែង និងទទួលការតែងតាំងថ្មី ជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ពិនិត្យឃើញឈ្មោះស្ទួននៅក្រសួង ស្ថាប័នផ្សេងៗ ចំនួន៣នាក់ និង
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ និងធ្វើរបាយការណ៍ ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុងនានា ព្រមទាំងកម្មវិធីផ្សេងៗ ចំនួន៥៧៣លើក។

## ៤.៤-ការងារស្រាវជ្រាវ៖

- បានតាមដានអំពី៖
  - ការអនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។
  - វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យនានា។
  - ការអនុវត្តយុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤-២០២៨ និង
  - ការអនុវត្តគោលនយោបាយស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨។
- បានតាមដាន និងសិក្សាលើរបាយការណ៍និន្នាការសេដ្ឋកិច្ច-សង្គម ប្រចាំខែ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតី ព្រមទាំងធ្វើបទបង្ហាញក្នុងវេទិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ស្តីពី " ពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងសហគ្រិនស្ត្រី រួមទាំងវិស័យឌីជីថល " នៅខេត្តកំពត។
- បានចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីសង្ខេបស្តីពី ការផ្ទេរធនធានថវិកាជូនមូលនិធិឃុំ-សង្កាត់ ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងប្រភេទប័ណ្ណសម្រាប់ប្រើប្រាស់សេវាថែទាំសុខភាពដោយឥតគិតថ្លៃ តាមសំណើរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣។
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៩១-៩៦ ឆ្នាំ២០២៣)។
- បានបញ្ចូលទិន្នន័យថវិកាចំណូល-ចំណាយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច (TOFE) ប្រចាំខែ ក្នុងឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២០៣ព័ត៌មាន។

## ៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១៣លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X (Former Twitter), Youtube, Telegram និងTiktok ចំនួន១,៤២៦លើក។

- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន៤៥៥ប្រធានបទ។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃព្រឹទ្ធសភាចំនួន ១,១៥៤ ប្រធានបទ។
- បានអញ្ជើញអ្នកសារព័ត៌មានទូរទស្សន៍ជាតិកម្ពុជា ចូលយកព័ត៌មាន ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្តែងការគួរសម ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៩លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១០លើក។
- បានរៀបចំផលិតៈ
  - ប្រតិទិនការងារឆ្នាំ២០២៥ ចំនួន៤៥០ក្បាល។
  - សៀវភៅទិនានុលេខន៍របស់ព្រឹទ្ធសភា ឆ្នាំ២០២៥ ចំនួន១,៥០០ក្បាល និង
  - ទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥ ចំនួន៨០០ក្បាល។
- បានចងក្រងព្រឹត្តិបត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន ប្រចាំសប្តាហ៍នៃខែមករា ឆ្នាំ២០២៥ ចំនួន២៧ ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ិនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១៧២គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា និងប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ(Digital) ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន៤០លើក។
- បានទទួលឯកសារ ទស្សនាវដ្តី សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៣ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន២ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៥៩៥ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៣នាក់ (គិតត្រឹមខែមករា ឆ្នាំ២០២៥) និង
- បានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា ក្នុងផេក TikTok របស់បណ្ណាល័យព្រឹទ្ធសភា (មាន Follower ចំនួន២៤នាក់ និងអ្នក Like ចំនួន២៩នាក់)។

**៩.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៣៦លើក។
- បានរៀបចំលិខិតឆ្លើយតបជាភាសាអង់គ្លេស និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា ចំនួន៣ច្បាប់/លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតរំលែកទុក្ខ ព្រមទាំងកន្ត្រកផ្កា កន្ត្រកផ្លែឈើ ជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ ថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ចំនួន៤៤លិខិត កន្ត្រកផ្កា ចំនួន១៨កន្ត្រក និងកន្ត្រកផ្លែឈើ ចំនួន៦កន្ត្រក។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការជូនសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំនួន៣រូប។
- បានផលិត និងផ្សព្វផ្សាយ " ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមករា ឆ្នាំ២០២៥ " ចំនួន ១ច្បាប់។
- បានរៀបចំឯកសារជំនួយស្មារតីស្តីពី កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងព្រឹទ្ធសភានៃសាធារណរដ្ឋហ្វីលីពីន។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៦ច្បាប់ និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងចងបដាពាក្យស្លោក ដាក់តាំងប៉ាណូអបអរសាទរខួបលើកទី៤៦ ទិវាជ័យជម្នះ៧មករា។

**៩.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងធ្វើរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋាន ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែមករា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែមករា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន៤២លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែមករា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ ចំនួន៤ច្បាប់៖
  - ១- សេចក្ដីព្រាងច្បាប់ស្ដីពី ជលផល។
  - ២-សេចក្ដីព្រាងច្បាប់ស្ដីពី ការទទួលខុសត្រូវលើផលិតផលមានវិការៈ។
  - ៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង
  - ៤-សេចក្ដីព្រាងច្បាប់ស្ដីពី ការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក។
- ត្រៀមរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា របស់រាជរដ្ឋាភិបាល ក្នុងរយៈពេលវិស្សមកាល៣ខែ ចាប់ពីថ្ងៃទី៦ ខែមករា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។
- ខុទ្ទកាល័យថ្នាក់ដឹកនាំទាំង៣ ការិយាល័យជំនួយការគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមសមាជិកាព្រឹទ្ធសភា ត្រៀមធ្វើរបាយការណ៍ស្ដីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នីតិកាលទី៥ នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ និង
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ត្រៀមចុះជួបសំណេះសំណាលជាមួយថ្នាក់ខេត្ត ដើម្បីស្វែងយល់អំពីការអនុវត្តតួនាទី ភារកិច្ច ក្នុងការអនុវត្តច្បាប់ និងការផ្ដល់សេវាសាធារណៈ នៅខេត្តប៉ៃលិន។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។
- ត្រៀមផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា រួមមាន៖
  - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ត្រៀម៖

    ១/ ចុះប្រាស្រ័យទាក់ទងជាមួយអង្គបោះឆ្នោត តាមដាន និងវាយតម្លៃពីដំណោះស្រាយបញ្ហាប្រឈម និងសំណូមពរចន្លោះសម័យប្រជុំលើកទី១ និងលើកទី២

    ២/ បន្តស្វែងយល់បញ្ហាប្រឈម សំណូមពរ របស់អាជ្ញាធរខណ្ឌទាំង១៤ និង

៣/ សំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ នាយប៉ុស្តិ៍នគរបាលទាំង១០៥ ផ្សព្វផ្សាយច្បាប់ថ្មីៗ ដែលព្រឹទ្ធសភាបានអនុម័ត និងបច្ចុប្បន្នភាពសភាពការណ៍ នៅខណ្ឌឫស្សីកែវ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌសែនសុខ ខណ្ឌកំបូល និងខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។

- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ទី២ និងទី៤ ត្រៀមសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តសមាគមរបស់សាធារណរដ្ឋបារាំង អញ្ជើញចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខណ្ឌព្រែកព្នៅ ខណ្ឌ៧មករា ខណ្ឌទួលគោក រាជធានីភ្នំពេញ និងមណ្ឌលសុខភាពក្រុងសួង ខេត្តត្បូងឃ្មុំ និងខេត្តបាត់ដំបង។
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទី៥ និងទី៨ ត្រៀមចុះជួបសំណេះសំណាលជាមួយអង្គបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្តល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការងារអភិវឌ្ឍមូលដ្ឋាន ព្រមទាំងចូលរួមដោះស្រាយ និងនាំយកយោបល់សំណូមពរ ឬបញ្ហានានា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅខេត្តកំពត ខេត្តត្បូងឃ្មុំ និងខេត្តស្ទឹងត្រែង។
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ត្រៀមចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋពិភាក្សាការងារ ជាមួយអាជ្ញាធរដែនដី ដើម្បីស្វែងយល់អំពីបញ្ហាប្រឈម សំណូមពរ ដំណោះស្រាយ ការអភិវឌ្ឍមូលដ្ឋាន និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន នៅស្រុកកណ្តាលស្ទឹង ស្រុកស្អាង ស្រុកកោះធំ ស្រុកកៀនស្វាយ ស្រុកលើកដែក ក្រុងសំពៅពូន ខេត្តកណ្តាល និង
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ត្រៀមចុះស្វែងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅបន្ត តាមដានវឌ្ឍនភាពការងារបន្តពីបេសកកម្មលើកមុន ផ្សព្វផ្សាយច្បាប់ថ្មីៗដែលព្រឹទ្ធសភាបានអនុម័ត និងធ្វើបច្ចុប្បន្នភាពសភាពការណ៍ នៅខេត្តព្រៃវែង។

- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងសិស្ស និស្សិតមកកាន់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋឥណ្ឌូណេស៊ី និង
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តការចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

សម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥ បានបិទបញ្ចប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៥។

វិស្សមកាលរបស់ព្រឹទ្ធសភា ចាប់ផ្តើមពីថ្ងៃទី៦ ខែមករា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥។ អនុលោមតាមប្រការ៥៥ វាក្យខ័ណ្ឌទី១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភា បានចាប់ផ្តើមចុះមូលដ្ឋាន ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគរបស់ខ្លួនតាមរយៈការអនុវត្តមុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់ ក្នុងស្មារតីម្ចាស់ការ និងទទួលខុសត្រូវខ្ពស់។

ស្ថិតក្នុងបរិបទខាងលើនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំយកចិត្តទុកដាក់ផ្តល់សេវាឆ្លើយតបនឹងតម្រូវការ និងសំណូមពរការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការបំពេញមុខងាររបស់ខ្លួនទទួលបានលទ្ធផលល្អប្រសើរ។

ក្រៅពីផ្តល់សេវានៅមូលដ្ឋាន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានផ្តល់សេវារៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងរៀបចំជំនួបសម្តែងការគួរសម និងពិភាក្សាការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជាមួយភ្ញៀវជាតិ និងអន្តរជាតិ បានដោយរលូនទទួលបានលទ្ធផលផ្លែផ្កា ជាគុណប្រយោជន៍ជូនជាតិមាតុភូមិ។

ថ្ងៃច័ន្ទ ៩រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**